# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តតាកែវ**

សំណុំរឿងព្រហ្មទណ្ឌលេខ: ៩៦៨
ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២
ជំនុំជម្រះ
លេខ: ៩០១
ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣
សាលក្រម
លេខ: ៩៦ "ក"
ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាដំបូងខេត្តតាកែវ នាថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤ វេលាម៉ោង ១០ និង ៣០ នាទីព្រឹក ដោយមានសមាសភាពដូចតទៅ:

**សមាសភាពជំនុំជម្រះ**

លោកជំទាវ [redacted] ប្រធានសាលាដំបូងខេត្តតាកែវ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

**ដើម្បីជំនុំជម្រះ**

លើពិរុទ្ធជនឈ្មោះ [redacted] កេវ ភេទប្រុស កើតឆ្នាំ១៩៧៣ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងមានទីលំនៅមុនពេលឃុំខ្លួនភូមិ [redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] ចាយ (ស្លាប់) ម្តាយឈ្មោះ [redacted] គីម (ស្លាប់) ប្រពន្ធឈ្មោះ [redacted] វន្នា (ស្លាប់) មានកូនចំនួន ០៤នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន គ្មាន ។ (ឃុំខ្លួនថ្ងៃទី២៧.០៧.២០២៤)

ជាប់ចោទពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ប្រព្រឹត្តនៅចំណុចភូមិកំពង់ជ្រៃ ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ កាលពីថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២១៩ នៃក្រមព្រហ្មទណ្ឌ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យពិរុទ្ធជនឈ្មោះ [redacted] កេវ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ិន ភេទប្រុស កើតឆ្នាំ១៩៧៩ ជនជាតិខ្មែរ មុខរបរលក់ដូរ មានទីកន្លែងកំណើតភូមិ [redacted] ខេត្តកំពត និងមានទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] ហាង (រស់) ម្តាយឈ្មោះ [redacted] សៀក (រស់) ប្រពន្ធឈ្មោះ [redacted] ចិន្តា (រស់) មានកូនចំនួន០៤នាក់ ទោសពីមុន គ្មាន ។



Scanned with CamScanner

-លោក [redacted] ជាមេធាវីការពារផលប្រយោជន៍ឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ។

-បានឃើញ: ដីកាសន្និដ្ឋានស្ថាពរលេខ: ១៥៧ ដ.ស.ព/២០២៣ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តតាកែវ ។

-បានឃើញ: ដីកាដំណោះស្រាយលេខ: ១៦១ ត.ព្រ/២០២៣ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ ។

-បានឃើញ: ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ៤០១ ដចត/២០២៣ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តតាកែវ ។

-បានឃើញ: សាលក្រមព្រហ្មទណ្ឌលេខ: ៣៦ "ក" ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤ របស់ សាលាដំបូងខេត្តតាកែវ ។

-បានឃើញ: ដីកាបង្គាប់ឱ្យចាប់ខ្លួនពិរុទ្ធជនលេខ: ២៦៥/២០២៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤ របស់ចៅក្រមជំនុំជម្រះនៃសាលាដំបូងខេត្តតាកែវ ។

-បានឃើញ: របាយការណ៍លេខ: ០៦១ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤ របស់ស្នងការដ្ឋាននគរបាលខេត្តតាកែវ ។

-បានឃើញ: កំណត់ហេតុស្ដីពីការជូនដំណឹងពីសាលក្រមកំបាំងមុខ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៤ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ ។

-បានឃើញ: សេចក្ដីចម្លងបណ្ដឹងទាស់លេខ: ១៤/២០២៤ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៤ របស់ពិរុទ្ធជនឈ្មោះ [redacted] កែវ ។

## អង្គហេតុចោទប្រកាន់

កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង ១៦ និង ៣០នាទី មានករណីអំពើហិង្សាមួយបានកើតឡើងស្ថិតនៅចំណុចភូមិកំពង់ជ្រៃ ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ បង្កឡើងដោយពិរុទ្ធជនឈ្មោះ [redacted] កែវ ភេទប្រុស អាយុ៤៨ឆ្នាំ បានធ្វើសកម្មភាពហាក់ធាក់ទៅលើជនរងគ្រោះឈ្មោះ [redacted] ខាំងអ៊ី ភេទប្រុស អាយុ១៤ឆ្នាំ បណ្ដាលឱ្យរងរបួសស្នាមជាំក្រោមដើមទ្រូង និងជនរងគ្រោះឈ្មោះ [redacted] ប៊ិន ភេទប្រុស អាយុ៤៩ឆ្នាំ បណ្ដាលឱ្យរបួសស្នាមបែកបបូរមាត់ ។ ក្រោយពេលទទួលពាក្យបណ្ដឹងពីជនរងគ្រោះ សមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកតុលាការ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

## នាពេលសវនាការ

-ពិរុទ្ធជនឈ្មោះ [redacted] កែវ មានវត្តមាន ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ិន មានវត្តមាន ។

-ជនរងគ្រោះឈ្មោះ [redacted] ខាំងអ៊ី អវត្តមាន ។

-សាក្សីឈ្មោះ [redacted] ម៉ាល័យ អវត្តមាន ។

-សាក្សីឈ្មោះ [redacted] លក្ខិណា អវត្តមាន ។

-សាក្សីឈ្មោះ [redacted] មឿន មានវត្តមាន ។

-សាក្សីឈ្មោះ [redacted] សារឿន មានវត្តមាន ។

-លោក [redacted] ជាមេធាវីការពារផលប្រយោជន៍ឱ្យដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ប៊ិន អវត្តមាន ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យពិរុទ្ធជនឈ្មោះ [redacted] កេវ មានវត្តមាន ។

-ពិរុទ្ធជនឈ្មោះ [redacted] កេវ បានឆ្លើយថា: ខ្ញុំបាទចូលមកសាលាដំបូងខេត្តតាកែវ នៅថ្ងៃនេះ គឺដើម្បីប្តឹងទាស់ទៅនឹងសាលក្រមលេខ: ៣៦ "ក" ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តតាកែវ ដែលបានសម្រេចផ្តន្ទាទោសខ្ញុំបាទដាក់ពន្ធនាគារចំនួន ២ (ពីរ) ឆ្នាំ និងសំណងជម្ងឺចិត្តចំនួន ១៥.០០០.០០០ (ដប់ប្រាំ) លានរៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ិន ពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ប្រព្រឹត្តនៅចំណុចភូមិកំពង់ជ្រៃ ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ កាលពីថ្ងៃ០៨ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។ ដែលកន្លងមកខ្ញុំបាទពុំដែលបានទទួលដំណឹងអំពីសាលក្រមដែលសម្រេចផ្តន្ទាទោសលើខ្ញុំបាទទេ ។ ក្នុងរឿងនេះខ្ញុំបាទសុំប្តឹងទាស់ សុំឱ្យតុលាការជំនុំជម្រះឡើងវិញ ។ ដោយសារនៅថ្ងៃកើតហេតុខ្ញុំបាទមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។ នៅថ្ងៃកើតហេតុខ្ញុំបាទស្រវឹងស្រាល្មមដែរ ហើយពេលកើតហេតុមានការប្រតាយប្រតប់គ្នា និងគុបស្បែកជើងដាក់គ្នាប្រាដកមែន ។ នៅក្នុងរឿងនេះខ្ញុំបាទ និងឈ្មោះ [redacted] ប៊ិន បានព្រមព្រៀងបញ្ចប់រឿងជាមួយគ្នាអស់ហើយដោយខ្ញុំបានយល់ព្រមកាត់ដីដែលមានជំលោះពីមុនមកឱ្យទៅឈ្មោះ [redacted] ប៊ិន រួចរាល់ហើយ ។ ខ្ញុំសូមសន្យាថា ពេលខ្ញុំចេញទៅរស់នៅក្នុងភូមិវិញ ខ្ញុំមិនរករឿងបង្កបញ្ហាដល់បុគ្គលណាម្នាក់ឡើយ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ិន បានឆ្លើយថា កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១៥ និង ០០នាទីរសៀល ខ្ញុំបាទកំពុងតែលក់ដូរអីវ៉ាន់នៅក្នុងផ្ទះស្រាប់តែលឺឈ្មោះ [redacted] លក្ខិណា ភេទស្រី អាយុ៣១ឆ្នាំ និងឈ្មោះ [redacted] ម៉ាល័យ ភេទស្រី អាយុ៣២ឆ្នាំ បានស្រែកហៅខ្ញុំបាទ និងប្រពន្ធរបស់ខ្ញុំបាទឱ្យមកជួយកូនរបស់ខ្ញុំបាទ ឈ្មោះ [redacted] ខាំងអ៊ី ភេទប្រុស អាយុ១៨ឆ្នាំ ដោយថាឈ្មោះ [redacted] កេវ ភេទប្រុស អាយុ៤៨ ឆ្នាំ បានវាយមកលើកូនរបស់ខ្ញុំបាទ ពេលនោះខ្ញុំបាទក៏បានរត់ចេញពីផ្ទះមកមើល តែពេលមកដល់ឈ្មោះ [redacted] កេវ ក៏បានរត់ទៅផ្ទះវិញហើយ ខ្ញុំបាទក៏បានដើរទៅក្រៀកករឈ្មោះ [redacted] កេវ ឱ្យមកកន្លែងកើតហេតុវិញពេលនោះឈ្មោះ [redacted] កេវ បានដាល់មាត់ខ្ញុំបាទជាច្រើនដៃ បណ្តាលឱ្យខ្ញុំបាទហូរឈាមជាច្រើន ។ បន្ទាប់មកខ្ញុំបាទក៏បាននាំកូនប្រុសឈ្មោះ [redacted] ខាំងអ៊ី ទៅមន្ទីរពេទ្យដើម្បីពិនិត្យ និងព្យាបាលរបួសដែលឈ្មោះ [redacted] កេវ បានវាយ និងពិនិត្យខ្ញុំបាទផងដែរ ។ ក្រោយពេលខ្ញុំបាទបានមកដល់មន្ទីរពេទ្យ ២៤ម៉ោង កំពង់ជ្រៃ គ្រូពេទ្យក៏បានដាក់សេរ៉ូមឱ្យកូនខ្ញុំបាទ និងបានឱ្យថ្នាំលេបយកមកផ្ទះវិញ ចំណែករូបខ្ញុំបាទគ្រាន់តែលេបថ្នាំតែប៉ុណ្ណោះ ដោយចំណាយប្រាក់អស់ចំនួន ១២០.០០០ (មួយសែន



Scanned with CamScanner

ពីរម៉ឺន) រៀល ។ នៅក្នុងរឿងនេះខ្ញុំបាទបានសុំដកពាក្យបណ្តឹងឈប់ប្តឹងលើឈ្មោះ [redacted] កេវ ដែលបានប្រើប្រាស់អំពើហិង្សាមកលើកូនរបស់ខ្ញុំបាទដូចដែលមាននៅក្នុងលិខិតសុំដកពាក្យបណ្តឹង ចុះថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០២៤ ហើយនៅក្នុងរឿងនេះដែរ រវាងខ្ញុំ និងឈ្មោះ [redacted] កេវ ក៏បានធ្វើកិច្ចព្រមព្រៀងបញ្ចប់វិវាទដែរ ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សារឿន បានឆ្លើយថា នៅថ្ងៃកើតហេតុ ខ្ញុំបាទកំពុងហូបជុំគ្នានៅផ្ទះរបស់ខ្ញុំបាទ ស្រាប់តែឈ្មោះ [redacted] កេវ បានទូរសព្ទហៅខ្ញុំមកហូបនៅផ្ទះរបស់គាត់ពេលទៅដល់ផ្ទះរបស់ឈ្មោះ [redacted] កេវ ខ្ញុំបានឃើញឈ្មោះ [redacted] កេវ កំពុងប្រតាយប្រតប់គ្នាជាមួយឈ្មោះ [redacted] ប៊ិន តែត្រូវបានឈ្មោះ [redacted] មឿន ជួយចាប់ឃាត់បំបែកចេញ ។ ចំពោះសកម្មភាពវាយតប់គ្នារវាងឈ្មោះ [redacted] កេវ និងឈ្មោះ [redacted] ប៊ិន ខ្ញុំបាទពុំបានឃើញនោះទេ ព្រោះមុនពេលដែលខ្ញុំបាទទៅដល់សកម្មភាពវាយតប់គ្នាបានជាប់ហើយ ។ ខ្ញុំមិនបានឃើញឈ្មោះ [redacted] កេវ និងឈ្មោះ [redacted] ប៊ិន ប្រើប្រាស់អំពើហិង្សាដាក់គ្នា ឬ អត់នោះទេ ព្រោះពេលទៅដល់កន្លែងកើតហេតុខ្ញុំបាទ គ្រាន់តែបានឃើញសកម្មភាពប្រតាយប្រតប់គ្នាតិចតួចប៉ុណ្ណោះ ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] មឿន បានឆ្លើយថា នៅថ្ងៃកើតហេតុខ្ញុំបាទមានកម្មវិធីហូបចុកតិចតួចជាមួយឈ្មោះ [redacted] សារឿន ក្រោយមកឈ្មោះ [redacted] កេវ បានទូរសព្ទហៅខ្ញុំនិងឈ្មោះ [redacted] សារឿន ទៅហូបស្រាបៀរបន្តនៅផ្ទះរបស់គាត់ ។ លុះពេលខ្ញុំបាទទៅដល់កន្លែងកើតហេតុស្រាប់តែឃើញឈ្មោះ [redacted] កេវ និងឈ្មោះ [redacted] ប៊ិន បានជេរប្រទិចគ្នាទៅវិញទៅមក ។ ឈ្មោះ [redacted] ប៊ិន បានកាន់ដែករវៃសំយ៉ាបផ្ទះនៅនឹងដៃដើម្បីការពារខ្លួន និងបម្រុងទុកវាឈ្មោះ [redacted] កេវ ហើយឈ្មោះ [redacted] កេវ បានរត់មកពួនក្រោយខ្នងរបស់ខ្ញុំបាទ ដើម្បីឱ្យខ្ញុំបាទជួយបាំងការពារ ។ ខ្ញុំបាទមិនបានឃើញឈ្មោះ [redacted] ប៊ិន ប្រើប្រាស់អំពើហិង្សាដាក់គ្នាជាមួយឈ្មោះ [redacted] កេវ ទេតែមុនពេលខ្ញុំទៅដល់កើតហេតុយ៉ាងណានោះ គឺខ្ញុំបាទពុំបានដឹងនោះទេ ។

-ក្រឡាបញ្ជីបានអានអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ខាំងអ៊ី ភេទប្រុស អាយុ១៨ឆ្នាំ បានឆ្លើយថា កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១៦ និង ០០នាទីរសៀល ខ្ញុំបាទបានត្រឡប់មកពីសាលារៀនវិញ ស្រាប់តែឃើញឈ្មោះ [redacted] កេវ ភេទប្រុស អាយុ៤៨ឆ្នាំ បានដើរចេញពីឡានមួយគ្រឿងសំដៅមកផ្ទះរបស់ខ្ញុំបាទ ហើយបានស្រែកជេរប៉ារបស់ខ្ញុំបាទថា អាប៊ិន អាឆ្កែ អាចោក ប្រយ័ត្នអញកាប់សម្លាប់តាមផ្លូវ ដោយនិយាយជាច្រើនដងពេកហើយព្រមទាំងបានធាក់ម៉ូតូប៉ារបស់ខ្ញុំបាទដែលបញ្ឈរនៅមុខផ្ទះបណ្តាលឱ្យដួលពេលនោះ ខ្ញុំបាទខឹងក៏បានជេរគាត់មួយមាត់ទៅវិញថា អាឆ្កែ ។ ភ្លាមៗនោះឈ្មោះ [redacted] កេវ ក៏ស្ទុះមកវាយដើមទ្រូវខ្ញុំបាទចំនួនមួយដៃចំមុខចំនួនមួយដៃ និងទះមុខខ្ញុំបាទជាច្រើនដៃ ព្រមទាំងបានទាត់ខ្ញុំបាទចំនួនមួយជើងទៀតផង ហើយខ្ញុំបាទក៏បានយកស្បែកជើងគប់ទៅលើឈ្មោះ [redacted] កេវ តែគប់មិនត្រូវហើយពេលនោះឈ្មោះ [redacted] លក្ខិណា បានស្រែកប្រាប់ម្តាយខ្ញុំបាទឱ្យមកជួយព្រោះ



Scanned with CamScanner

ឃើញឈ្មោះ [redacted] កេវ បានវាយមកលើខ្ញុំបាទខណៈពេលនោះប៉ារបស់ខ្ញុំបាទឈ្មោះ [redacted] ប៊ិន ក៏បានដើរចេញពីក្នុងផ្ទះហើយយកទូរសព្ទថត ។ បន្ទាប់មកឈ្មោះ [redacted] កេវ ក៏បានលូកដៃចេញមកពីផ្ទះ (ផ្ទះជាប់គ្នា) របស់គាត់មកវាយចំក្តោងច្រមុះខ្ញុំបាទ ចំនួនមួយដៃ ពេលនោះខ្ញុំបាទក៏បានជេរឈ្មោះ [redacted] កេវ ថាអាឆ្កែ អាថោក ហើយឈ្មោះ [redacted] កេវ ក៏បានរើសដុំថ្មមកគប់ត្រូវដៃរបស់ខ្ញុំបាទទៀតភ្លាមៗ នោះប៉ារបស់ខ្ញុំបាទក៏បានស្ទុះទៅក្រៀកករឈ្មោះ [redacted] កេវ ឱ្យដើរមកកន្លែងកើតហេតុហើយត្រូវឈ្មោះ [redacted] កេវ វាយជាច្រើនដៃចំមាត់ បណ្តាលឱ្យឈាម ហើយមានមនុស្សប្រុសពីរនាក់មកចាប់ដៃប៉ារបស់ខ្ញុំបាទ ចេញពីឈ្មោះ [redacted] កេវ ។ ក្រោយពេលកើតហេតុ ខ្ញុំបាទនិងប៉ារបស់ខ្ញុំបាទបានទៅមន្ទីរពេទ្យ២៤ម៉ោងកំពង់ជ្រៃ ហើយខ្ញុំបាទគ្រាន់តែត្រូវជាំដើមទ្រូង និងជាំដៃតែប៉ុណ្ណោះ ចំណែកប៉ារបស់ខ្ញុំបាទវិញគឺរងរបួសត្រូវចំមាត់ ។

-ក្រឡាបញ្ជីបានអានអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] លក្ខិណា ភេទស្រី អាយុ៣១ឆ្នាំ បានឆ្លើយថា កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១៧ និង ០០នាទីល្ងាច នាងខ្ញុំបានឃើញឈ្មោះ [redacted] កេវ ភេទប្រុស បានដើរមកធាក់ម៉ូតូរបស់ឈ្មោះ [redacted] ប៊ិន បណ្តាលឱ្យដួលហើយកូនប្រុសរបស់ឈ្មោះ [redacted] ប៊ិន ឈ្មោះ [redacted] ខាំងអ៊ី បានត្រឡប់មកពីសាលារៀនវិញ ក៏បានទៅលើកម៉ូតូហើយបាននិយាយទៅកាន់ឈ្មោះ [redacted] កេវ តែនាងខ្ញុំមិនបានដឹងថា និយាយអ្វីនោះទេ ។ បន្ទាប់មកឈ្មោះ [redacted] កេវ បានជេរប្រមាថទៅលើឈ្មោះ [redacted] ខាំងអ៊ី នូវពាក្យអសុរោះជាច្រើន តែនាងខ្ញុំមិនបានចាំទេ ។ មួយសន្ទុះក្រោយមកឈ្មោះ [redacted] កេវ បានលូកដៃមកវាយឈ្មោះ [redacted] ខាំងអ៊ី តែនាងខ្ញុំ មិនបានដឹងថាត្រូវកន្លែងណាខ្លះនោះទេ ។ ក្រោយមកស្រាប់តែឃើញឈ្មោះ ហ៊ុយ ប៊ិន និងឈ្មោះ [redacted] កេវ បានវាយប្រតាយប្រតប់គ្នា នាងខ្ញុំបានឃើញឈ្មោះ [redacted] ប៊ិន ត្រូវរបួសបែកមាត់ចំណែកឈ្មោះ [redacted] កេវ មិនបានឃើញត្រូវរបួសអ្វីនោះទេ ។

-ក្រឡាបញ្ជីបានអានអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ម៉ាល័យ ភេទស្រី អាយុ៣២ឆ្នាំ បានឆ្លើយថា កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១៧ និង ០០ នាទីល្ងាច នាងខ្ញុំបានឃើញឈ្មោះ [redacted] កេវ ភេទប្រុស បានដើរទៅធាក់ម៉ូតូរបស់ឈ្មោះ [redacted] ប៊ិន ឱ្យដួលហើយកូនប្រុសរបស់ឈ្មោះ [redacted] ប៊ិន ឈ្មោះ [redacted] ខាំងអ៊ី បានត្រឡប់មកពីសាលារៀនវិញ ឃើញដូច្នេះក៏បានទៅលើកម៉ូតូ និងបាននិយាយទៅកាន់ឈ្មោះ [redacted] កេវ ថាហេតុអ្វីបានជាហ្អែងធាក់ម៉ូតូប៉ារបស់អញ ។ បន្ទាប់មកឈ្មោះ [redacted] កេវ បានជេរប្រមាថទៅលើឈ្មោះ [redacted] ខាំងអ៊ី នូវពាក្យអសុរោះជាច្រើនតែនាងខ្ញុំមិនបានចាំនោះទេ ។ មួយសន្ទុះក្រោយមកទៀតឈ្មោះ [redacted] កេវ បានលូកដៃវាយទៅលើឈ្មោះ [redacted] ខាំងអ៊ី តែនាងខ្ញុំមិនបានដឹងថាត្រូវកន្លែងណាខ្លះនោះទេ ។ ក្រោយមកទៀតនាងខ្ញុំក៏បានឃើញឈ្មោះ [redacted] ប៊ិន និងឈ្មោះ [redacted] កេវ ប្រតាយប្រតប់គ្នា ហើយនាងខ្ញុំបានឃើញឈ្មោះ [redacted] ប៊ិន ត្រូវរបួសបែកមាត់ ចំណែកឯឈ្មោះ [redacted] កេវ មិនត្រូវរបួសអ្វីនោះទេ ។

-ក្រឡាបញ្ជីអានអំណានការអះអាងបញ្ចប់វិវាទរបស់ពិរុទ្ធឈ្មោះ [redacted] កេវ ដែលបាន...

ខ្លឹមសារបញ្ជាក់ថា ខ្ញុំបាទយល់ព្រមប្រគល់ដីទំហំ ០៣ (បី) ម៉ែត្រ ដែលវាស់ចាប់ពីជញ្ជាំងរឹងមាំដែលមានស្រាប់មានទីតាំងស្ថិតនៅភូមិកំពង់ជ្រៃ ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ ដោយស្ម័គ្រចិត្តគ្មានការជំទាស់អ្វីទាំងអស់ និងអំណានការអះអាងបញ្ចប់វិវាទរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ិន បានអះអាងថា ខ្ញុំបាទយល់ព្រមទទួលយកដីទំហំ ០៣ (បី) ម៉ែត្រ ដែលវាស់ចាប់ពីជញ្ជាំងរឹងមាំដែលមានស្រាប់មានទីតាំងស្ថិតនៅភូមិកំពង់ជ្រៃ ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ ដោយស្ម័គ្រចិត្តគ្មានការជំទាស់អ្វីទាំងអស់ ។ ខ្ញុំបាទជាភាគីដើមបណ្តឹង យល់ព្រមដកពាក្យបណ្តឹងទាំងអស់ ដែលខ្ញុំបាទធ្លាប់បានដាក់ប្តឹងកន្លងមកចាប់ពីពេលនេះតទៅ ។ យើងខ្ញុំជាភាគី សូមអះអាងថា ត្រូវអនុវត្តតាមកិច្ចព្រមព្រៀងនេះឱ្យបានខ្ជាប់ខ្ជួន និង ឱ្យមានប្រសិទ្ធិភាពខ្ពស់បំផុត ។ ក្នុងករណីដែលយើងខ្ញុំ ជាភាគីមិនអនុវត្តតាមកិច្ចព្រមព្រៀងនេះទេ យើងខ្ញុំយល់ព្រមទទួលខុសត្រូវចំពោះមុខច្បាប់ដែលនៅជាធរមានយ៉ាងពេញទំហឹង ។ ចំពោះការធ្វើកិច្ចព្រមព្រៀងបញ្ចប់វិវាទរបស់យើងខ្ញុំនៅពេលនេះ គឺកើតចេញពីឆន្ទៈរបស់យើងខ្ញុំដោយផ្ទាល់ ដោយពុំមានការបង្ខិតបង្ខំ គំរាមកំហែង ឬ ក៏ការលួងលោមពីបុគ្គលណាម្នាក់ឡើយ ។ ក្រែងពុំពិតប្រាកដ យើងខ្ញុំសូមផ្តិតស្នាមមេដៃទុកជាភស្តុតាង ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ក្រោយពីបានស្តាប់ការសួរដេញដោលនៅក្នុងអង្គសវនាការ ក្រោយពីបានស្តាប់ចម្លើយរបស់ពិរុទ្ធជន ក្រោយពីស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រោយពីបានស្តាប់ការបំភ្លឺរបស់សាក្សី និងក្រោយពីបានពិនិត្យឯកសារផ្សេងៗ ដែលមានក្នុងសំណុំរឿងរួចមក ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ដែលមាននៅក្នុងដីកាសន្និដ្ឋានស្ថាពរប្រាកដមែន ។ ដូច្នេះតំណាងអយ្យការ ស្នើសុំឱ្យតុលាការផ្តន្ទាទោសទៅលើជនជាប់ចោទតាមច្បាប់ និងរក្សាបទចោទប្រកាន់ទុកនៅដដែល ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យពិរុទ្ធជនឈ្មោះ [redacted] កេវ បានធ្វើសេចក្តីសន្និដ្ឋានការពារដល់កូនក្តីថា ក្រោយពីបានពិភាក្សាដេញដោល ក្រោយពីបានស្តាប់ចម្លើយកូនក្តីខ្ញុំបាទ ក្រោយពីបានស្តាប់ចម្លើយរបស់ដើមរដ្ឋប្បវេណី និងក្រោយពីបានស្តាប់ចម្លើយរបស់សាក្សីនានា ឃើញថាកូនក្តីខ្ញុំបាទឈ្មោះ [redacted] កេវ ពុំបានប្រព្រឹតដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ ព្រោះពុំមានភស្តុតាង និង សាក្សី ដាក់បន្ទុកគ្រប់គ្រាន់ថា កូនក្តីខ្ញុំបាទបានវាយទៅលើជនរងគ្រោះនោះឡើយ ។ តាមការអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង ផ្អែកតាមការបំភ្លឺរបស់សាក្សី គឺពួកគាត់បានឆ្លើយយ៉ាងច្បាស់ថា កូនក្តីខ្ញុំបាទឈ្មោះ [redacted] កេវ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ិន គឺបានប្រតាយប្រតប់ជាមួយគ្នាប៉ុណ្ណោះ ហើយក៏គ្មានសាក្សីណាមួយបានឃើញកូនក្តីរបស់ខ្ញុំបាន វាយទៅលើជនរងគ្រោះដូចទៅនឹងអង្គហេតុនៃរឿងក្តី ខាងលើនេះទេ ចំណែកឯកូនក្តី ខ្ញុំក៏បានឆ្លើយបញ្ជាក់ដែរថា រូបគេពុំបានដឹង និងពុំបានពាក់ព័ន្ធនឹងការចោទប្រកាន់ខាងលើនេះដែរ ។ ដោយឡែកនៅក្នុងពេលពិភាក្សាដេញដោលជាសា

ធារណៈនេះ ដើមបណ្តឹងរដ្ឋប្បវេណី គាត់ក៏បានឆ្លើយបញ្ជាក់យ៉ាងច្បាស់ហើយថា គាត់សុំដកពាក្យបណ្តឹងឈប់ប្តឹងលើកូនក្តីខ្ញុំបាទ ហើយក៏បានធ្វើកិច្ចព្រមព្រៀងបញ្ចប់វិវាទជាមួយនឹងកូនក្តីខ្ញុំបាទរួចរាល់ហើយដែរ ។ ហេតុដូចនេះក្នុងនាម ខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យកូនក្តីខ្ញុំបាទ សូមស្នើសុំដល់ចៅក្រមជំនុំជម្រះ មេត្តាសម្រេចឱ្យកូនក្តីខ្ញុំបាទបានរួចផុតពីបទចោទប្រកាន់ផង ។

-ពិរុទ្ធជនឈ្មោះ [redacted] កែវ បានសំណូមពរសុំដល់តុលាការ មេត្តាជួយរកយុត្តិធម៌ដល់រូបខ្ញុំបាទផង ដោយសម្រេចឱ្យខ្ញុំបាទបានរួចផុតពីការចោទប្រកាន់ ដោយហេតុថានៅថ្ងៃកើតហេតុខ្ញុំបាទពុំបានប្រព្រឹត្តដូចអង្គហេតុខាងលើនេះនោះទេ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ពិរុទ្ធជន ។

-ក្រោយពីបានស្តាប់អំណានការអះអាងរបស់ភាគី ។

-ក្រោយពីបានស្តាប់ការបំភ្លឺរបស់សាក្សី ។

-ក្រោយពីបានពិនិត្យឯកសារ និង ភស្តុតាងពាក់ព័ន្ធក្នុងសំណុំរឿង ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យពិរុទ្ធជន ។

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ពិរុទ្ធជន ។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

១-បណ្តឹងទាស់របស់ពិរុទ្ធជនឈ្មោះ [redacted] កែវ ភេទប្រុស កើតឆ្នាំ១៩៧៣ គឺធ្វើឡើងត្រឹមត្រូវតាមច្បាប់ ។ ហេតុដូច្នេះ គប្បីតុលាការលើកយកសំណុំរឿងព្រហ្មទណ្ឌលេខៈ ៤៦៨ ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តតាកែវ មកចាត់ការតាមច្បាប់ ។

២-តាមសាលក្រមព្រហ្មទណ្ឌលេខៈ ៣៦ "ក" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តតាកែវ ពិរុទ្ធជនមានសិទ្ធិប្តឹងទាស់លើសាលក្រម ដែលតុលាការបានសម្រេចសេចក្តីកំបាំងមុខតាមបញ្ញត្តិមាត្រា ៣៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយចំពោះពិរុទ្ធជនឈ្មោះ [redacted] កែវ បានប្តឹងទាស់លើសាលក្រមខាងលើនេះ ដោយបានប្តឹងទាស់គ្រង់សេចក្តីសម្រេចដែលបានផ្តន្ទាទោសដល់ខ្លួន ។ ហេតុដូច្នេះគប្បីតុលាការ ទទួលយកបណ្តឹងទាស់នេះមកជំនុំជម្រះ និង សម្រេចសារជាថ្មីម្តងទៀតបានតាមបញ្ញត្តិមាត្រា ៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-តាមលិខិតសុំដកពាក្យបណ្តឹង ចុះថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០២៤ របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ប៊ិន និង តាមរយៈកិច្ចព្រមព្រៀងបញ្ចប់វិវាទ ចុះថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០២៤ ដែលធ្វើឡើងរវាងដើមបណ្តឹងរដ្ឋប្បវេណី និង ពិរុទ្ធជន ឃើញថាដើមបណ្តឹងរដ្ឋប្បវេណី ពិតជាមានឆន្ទៈក្នុងការបញ្ចប់វិវាទជាមួយនឹងពិរុទ្ធជន ប្រាកដមែន ។

៤-ការសុំដកពាក្យបណ្តឹង និង ការធ្វើកិច្ចព្រមព្រៀងបញ្ចប់វិវាទ របស់ដើមបណ្តឹង



Scanned with CamScanner

រដ្ឋប្បវេណី គឺបានធ្វើឡើងដោយឆន្ទៈពិតប្រាកដ និង ដោយផ្ទាល់ ពុំមានការបង្ខិតបង្ខំ ការគំរាមកំហែង និង ការលួងលោមណាមួយឡើយ ។

៥-អំពើប្រព្រឹត្តរបស់ជនជាប់ចោទ គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសង្គម ។ គប្បីតុលាការពិចារណាក្នុងការដាក់ទណ្ឌកម្មលើជនជាប់ចោទ ។

៦-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] កេវ ភេទប្រុស កើតឆ្នាំ១៩៧៣ (អត្តសញ្ញាណខាងលើ) ពីបទៈ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចភូមិកំពង់ជ្រៃ ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ កាលពីថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៩ នៃក្រមព្រហ្មទណ្ឌ ។

៧-ឈ្មោះ [redacted] ប៊ិន ភេទប្រុស កើតឆ្នាំ១៩៧៩ ជាដើមបណ្តឹងរដ្ឋប្បវេណីបានថា នៅក្នុងរឿងនេះ ខ្ញុំបាទបានសុំដកពាក្យបណ្តឹងឈប់ប្តឹងលើឈ្មោះ [redacted] កេវ ដែលបានប្រើប្រាស់អំពើហិង្សាមកលើកូនរបស់ខ្ញុំបាទ ដូចដែលមាននៅក្នុងលិខិតសុំដកពាក្យបណ្តឹងចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៤ និងយល់ព្រមដកពាក្យបណ្តឹងទាំងអស់ដែលខ្ញុំបាទធ្លាប់បានដាក់ប្តឹងកន្លងមកចាប់ពីពេលនេះតទៅ ។ គប្បីតុលាការ ទទួលយកមកពិចារណាសម្រេចតាមភាពជាក់ស្តែង ។

៨-ការតម្កល់បទចោទប្រកាន់របស់តំណាងអយ្យការ តាមដីកាសន្និដ្ឋានស្ថាពរ ក្នុងពេលសវនាការដោយស្នើសុំឱ្យតុលាការផ្តន្ទាទោសទៅលើជនជាប់ចោទតាមច្បាប់ និងរក្សាទុកបទចោទប្រកាន់ទុកនៅដដែល ។ គប្បីតុលាការ ពិចារណាសម្រេចតាមអង្គហេតុ និង អង្គច្បាប់ ។

៩-សេចក្តីសន្និដ្ឋានការពាររបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនចោទឈ្មោះ [redacted] កេវ ដោយបានស្នើសុំដល់តុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីការចោទប្រកាន់ ដោយសំអាងថានៅក្នុងអង្គហេតុនេះ កូនក្តីខ្លួនពុំបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់នោះទេ ។ គប្បីតុលាការពិចារណា និង សម្រេច ។

## ហេតុដូច្នេះសម្រេច

១.ទទួលបណ្តឹងទាស់ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០២៤ របស់ពិរុទ្ធជនឈ្មោះ [redacted] កេវ ភេទប្រុស កើតឆ្នាំ១៩៧៣ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២.កែប្រែសាលក្រមលេខៈ ៣៦ "ក" ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តតាកែវ ។

៣.លើកចោលសំណងដែលពិរុទ្ធជនឈ្មោះ [redacted] កែវ ភេទប្រុស កើតឆ្នាំ១៩៧៣ សងសំណងជម្ងឺចិត្តចំនួន ១៥.០០០.០០០៛ (ដប់ប្រាំលាន) រៀល ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ិន ។

៤.ផ្តន្ទាទោសលើពិរុទ្ធជនឈ្មោះ [redacted] កេវ ភេទប្រុស កើតឆ្នាំ១៩៧៣ ជនជាតិខ្មែរ



Scanned with CamScanner

(ក្នុងឃុំ) ដាក់ពន្ធនាគារកំណត់រយៈពេល ២ (ពីរ) ឆ្នាំ តែទោសនេះត្រូវព្យួរជាធម្មតា ពីបទៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ប្រព្រឹត្តនៅចំណុចភូមិកំពង់ជ្រៃ ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ កាលពីថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០២២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៩ នៃក្រមព្រហ្មទណ្ឌ ។

៥.បញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួន ពិរុទ្ធជនឈ្មោះ [redacted] កែវ ភេទប្រុស កើតឆ្នាំ ១៩៧៣ លេខៈ ២៦៥/២៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤ ដែលចេញដោយចៅក្រមជំនុំជម្រះ នៃសាលាដំបូងខេត្តតាកែវ ។

-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០២៤ ចំពោះមុខពិរុទ្ធជនឈ្មោះ[redacted] កែវ និង ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ិន ។

-ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ៕

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ១១ កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
តាកែវ, ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤
**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ
**ចៅក្រមជំនុំជម្រះ**

[redacted]